BMI0055

# សម្ភាសន៍ជាមួយឈ្មោះ ហ៊ឹ ស្រិ ភេទស្រី អាយុ៦៤

មុខងារខ្មែរក្រហមៈ ធ្វើពេទ្យ

មុខងារបច្ចុប្បន្នៈ ធ្វើចំការនឹងស្រែ

ស្រុកកំណើតនៅៈ ភូមិកោះធំ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល

សព្វថ្ងៃរស់នៅៈ ភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៤៥:០០

២០ទំព័រ

ដានី ៈ ជំរាបសួរ អ៊ំ! ខ្ញុំចង់ស្គាល់ឈ្មោះអ៊ំៗ ឈ្មោះអីដែរ?

ស្រិ ៈ ឈ្មោះ ស្រិ

ដានី ៈ ត្រកូលអីស្រិដែល?

ស្រិ ៈ ហ៊ឹ ស្រិ

ដានី ៈ ហ៊ឹ ស្រិ?

ស្រិ ៈ ចាំ!

ដានី ៈ អ៊ំឈ្មោះអ៊ំអញ្ចឹងរហូតបុក៏មានផ្លាស់ប្តូរ ឈ្មោះកំណើតអ៊ំឪពុកម្តាយដាក់ឲ្យឈ្មោះអីទៅ?

ស្រិ ៈ ឈ្មោះអញ្ចឹងដដែល!

ដានី ៈ ឈ្មោះអញ្ចឹងអត់មានប្រែទេ?

ស្រិ ៈ អត់មានប្រែទេ ។

ដានី ៈ បាទ!អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ស្រិ ៈ អាយុ៦៤ឆ្នាំ

ដានី ៈ អ៊ំសព្វថ្ងៃរស់នៅភូមិអីដែរ ភូមិនេះ?

ស្រិ ៈ ភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ដានី ៈ អ៊ំប្រុសគាត់ឈ្មោះអីដែរ?

ស្រិ ៈ អ៊ំប្រុសឈ្មោះ យ៉ាត ។

ដានី ៈ អីយ៉ាត?

ស្រិ ៈ ស យ៉ាត

ដានី ៈ គាត់អាយុប៉ុន្មានដែរ?

ស្រិ ៈ អាយុ៦៥ឆ្នាំ ។

ដានី ៈ បងអ៊ំ១ឆ្នាំ?

ស្រិ ៈ ចា៎!

ដានី ៈ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរមកដល់សព្វថ្ងៃ?

ស្រិ ៈ មាន១នាក់ទេ ។

ដានី ៈ ស្រី ឬ ប្រុសម្នាក់?

ស្រិ ៈ ស្រី

ដានី ៈ អ៊ំសព្វថ្ងៃប្រកបរបររកស៊ីអីដែរ?

ស្រិ ៈ ធ្វើចំការ ។

ដានី ៈ ធ្វើស្រែដែរ?

ស្រិ ៈ ធ្វើ

ដានី ៈ ចុះអ៊ំស្រុកកំណើតអ៊ំនៅណាទៅ?

ស្រិ ៈ ស្រុកកំណើតនៅភូមិកោះធំ ឃុំកោះធំ ស្រុកកោះធំ ។

ដានី ៈ ឪពុកម្ដាយអ៊ំគាត់ឈ្មោះអីទៅ?

ស្រិ ៈ គាត់ស្លាប់បាត់យូរហើយ ។

ដានី ៈ បាទ!គាត់ឈ្មោះអីទេ?

ស្រិ ៈ ឪពុកឈ្មោះ ចន ។

ដានី ៈ ចុះម្ដាយឈ្មោះអី?

ស្រិ ៈ ម្ដាយឈ្មោះ ទង ។

ដានី ៈ គាត់ស្លាប់តាំងពីអន្កាល?

ស្រិ ៈ គាត់តាំងពីយូរណាស់ហើយ ម៉ែខ្ញុំស្លាប់តាំងពីខ្ញុំនៅតូចនោះតាំងខ្ញុំនៅកូនដ៏តនោះ ។

ដានី ៈ ចុះឪពុក?

ស្រិ ៈ ឪពុកមិនដឹងស្លាប់តាំងពី៧០ប៉ុន្មានទេខ្ញុំមិនដឹងដែរ ព្រោះនៅនេះជាប់គាត់នោះខ្ញុំនៅនេះ ទៅតាំងពីគេអត់ទាន់ចប់សង្គ្រាមនោះ ស្លាប់កាលនៅសង្គ្រាមខ្ញុំមិនហានទៅផង ។

ដានី ៈ ដឹងដែរដឹងថាគេប្រាប់ដែរ?

ស្រិ ៖ ដឹងគេម៉ោគេប្រាប់ ខ្ញុំមិនហានទៅ ។

ដានី ៖ បាទ!អ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ស្រិ ៖ បងប្អូនបង្កើត៦នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស្រិ ៖ ស្រីទាំងអស់ ។

ដានី ៖ ចុះអ៊ំទីប៉ុន្មាន?

ស្រិ ៖ ខ្ញុំទី១ ខ្ញុំបងគេបង្អស់ ។

ដានី ៖ ចុះអ៊ំពីដើមពីសង្គមអ៊ំរៀនដល់ថ្នាក់ណាដែរ?

ស្រិ ៖ ហ៊ឺ!គ្មានបានរៀនអីផងខ្ញុំ រៀនចេះអក្ខរកម្មតិចតួច ។

ដានី ៖ អត់បានរៀនទេ?

ស្រិ ៖ ចា៎!

ដានី ៖ ចេះអក្សរ ចេះអានអីឬអត់?

ស្រិ ៖ ចេះតិចតួច មើលរួចតិចៗមិនសូវចេះដែរ ។

ដានី ៖ ចុះកាលពីមុនសង្គ្រាមអ៊ំនៅជាមួយឪពុកម្ដាយ?

ស្រិ ៖ នៅជាមួយឪពុកម្ដាយ ។

ដានី ៖ ចុះអ៊ំរៀបការឆ្នាំណាទៅ?

ស្រិ ៖ ខ្ញុំរៀបការឆ្នាំ៧៦ ការសម័យសង្គ្រាមហ្នឹង ។

ដានី ៖ ការកាលឆ្នាំ៧៦ កាលសម័យ៣ឆ្នាំ?

ស្រិ ៖ ចា៎!

ដានី ៖ ចុះមុន៣ឆ្នាំអ៊ំមានតស៊ូអីដែរឬអត់?

ស្រិ ៖ តស៊ូដែរ ។

ដានី ៖ អ៊ំតស៊ូពីអង្កាល ចេញពីផ្ទះតាំងពីអង្កាល?

ស្រិ ៖ តស៊ូ ចេញពីផ្ទះឆ្នាំ៧០ ឬ៧១ទេ ឆ្នាំ៧១ ។

ដានី ៖ ក្រោយពីរដ្ឋប្រហារទំលាក់សម្ដេចហើយ?

ស្រិ ៖ ចា៎!

ដានី ៖ កាលហ្នឹងអ៊ំទៅតស៊ូនៅណាទៅ?

ស្រិ ៖ នៅនឹងភូមិនឹងម៉ង ។

ដានី ៖ អ៊ំតស៊ូហ្នឹងធ្វើអីខ្លះទៅ?

ស្រិ ៖ នៅកាត់ដេ នៅមន្ទីរតម្បាញអញ្ចឹងទៅ ។

ដានី ៖ កាលហ្នឹងនៅមន្ទីរតម្បាញរបស់ភូមិឃុំហ្នឹង?

ស្រិ ៖ ចា៎!ហ្នឹងហើយ ។

ដានី ៖ របស់ស្រុកដែរឬអត់ទេ?

ស្រិ ៖ មិនដឹងយ៉ាងម៉េច កាលហ្នឹងនិយាយរួមរបស់តំបន់ ។

ដានី ៖ របស់តំបន់ណា?

ស្រិ ៖ របស់តំបន់២៥ ។

ដានី ៖ កាលហ្នឹងអ៊ំនៅកាត់ដេតម្បាញ?

ស្រិ ៖ ចា៎!

ដានី ៖ កាត់ដេតម្បាញឲ្យទៅតំបន់?

ស្រិ ៖ ចា៎!

ដានី ៖ កាលហ្នឹងអ៊ំទៅតស៊ូតាមរយៈពីណាគេ?

ស្រិ ៖ មិនដឹងពីណាទេ ភ្លេចអស់ហើយ ចេះតែម៉ោបន្តៗគ្នាមិនដឹងណាណីទេភ្លេចអស់ហើយ ។

ដានី ៖ ចុះកាលហ្នឹងអ៊ំស្គាល់តាសុក តាអីដែរ?

ស្រិ ៖ តាសុកណា?

ដានី ៖ តាសុកគណៈតំបន់ តាសុក ប៊ុត ចំរើន?

ស្រិ ៖ ស្គាល់ ធ្លាប់ស្គាល់គាត់ដែរ ។

ដានី ៖ ធ្លាប់ធ្វើការជាមួយគាត់ដែរឬអត់?

ស្រិ ៖ ធ្លាប់ធ្វើជាមួយគាត់ខ្លះទៅ អត់ខ្លះទៅ ចេញម៉ោចេះតែធ្វើបន្តមកទៀតម៉ោ ។

ដានី ៖ ធ្វើការនៅភូមិហ្នឹងរហូតដល់ពេលណាទៅ?

ស្រិ ៖ ធ្វើនៅភូមិទាល់តែគេរៀបការឲ្យជាមួយយួនហ្នឹង ។

ដានី ៖ អ៊ូចុះបែក៧៥?

ស្រិ ៖ ពេលបែក៧៥ខ្ញុំម៉ោនៅភ្នំពេញ ។

ដានី ៖ ម៉េចបានអ៊ំផ្លាស់ទៅនៅភ្នំពេញគេផ្លាស់?

ស្រិ ៖ គេផ្លាស់ប្តូរម៉ោ ។

ដានី ៖ គេផ្លាស់ម៉ោឬអ៊ំចង់ម៉ោដែរ?

ស្រិ ៖ គេផ្ទាស់ ខ្ញុំចង់ម៉ោដែរហ្នឹង គេដកម៉ោភ្នំពេញហើយម៉ោនឹងគេទៅ ។

ដានី ៖ អ៊ំម៉ោនៅភ្នំពេញម៉ោនៅណា?

ស្រិ ៖ ម៉ោនៅភ្នំពេញម៉ោនៅម្តុំតាខ្មៅ ។

ដានី ៖ ឆ្នាំ៧៩ពេលបែកហ្នឹងគេផ្ទាស់អ៊ំម៉ោនៅភ្នំពេញបណ្តោយ?

ស្រិ ៖ ចា៎!

ដានី ៖ ចុះកាលនៅតាខ្មៅធ្វើអីទៅ?

ស្រិ ៖ កាលនៅតាខ្មៅធ្វើពេទ្យ ។

ដានី ៖ ចុះអ៊ំមកដល់ធ្វើពេទ្យតែម្តងឬមានរៀនពេទ្យ?

ស្រិ ៖ រៀនដែរ រៀនពីជនបទម៉ោខ្លះហើយ ។

ដានី ៖ រៀនម៉ោៗដល់តាខ្មៅធ្វើពេទ្យ គេហៅពេទ្យអីទៅ?

ស្រិ ៖ ពេទ្យអីទេកាលហ្នឹង ពេទ្យព្យាបាលកម្មករ ។

ដានី ៖ កម្មករនៅណា?

ស្រិ ៖ កម្មករនៅតាមរោងចក្រអីហ្នឹង ។

ដានី ៖ រោងចក្រនៅណា?

ស្រិ ៖ រោងចក្រនៅភ្នំពេញហ្នឹង ។

ដានី ៖ រោងចក្រនៅភ្នំពេញ ប៉ុន្តែរោងចក្រនៅភ្នំពេញវាមានច្រើនកន្លែង?

ស្រិ ៖ អត់ទេមកដេកពេទ្យនៅហ្នឹងទាំងអស់ម៉ង ដេកពេទ្យតាខ្មៅទាំងអស់ ហើយកន្លែងគេដាក់មុន មិនគេដាក់កន្លែងចិញ្ចឹមព្រាប នៅកន្លែងតាខ្មៅនៅកន្លែងគេដាក់កំពូលត្រីផ្ទុះខ្ពស់ហ្នឹងឯង ។

ដានី ៖ ជិតព្រែកគ្នោត?

ស្រិ ៖ ចា៎!

ដានី ៖ ពេទ្យព្រែកគ្នោតហ្នឹងម៉ង?

ស្រិ ៖ អត់ទេ នៅខាងលើនេះនៅតាខ្មៅខាងលើនេះ នៅកន្លែងរោងចក្រផង្គនោះ ស្គាល់រោងចក្រផង្គអត់?

ដានី ៖ ខ្ញុំអត់ស្គាល់រោងចក្រផង្គផង?

ស្រិ ៖ ហ្នឹងហើយកន្លែងរោងចក្រផង្គហ្នឹងហើយ កន្លែងគេដាក់ដូចយាស៊ូអញ្ចឹង មានត្រីឆ្លាងចេះនោះ ។

ដានី ៖ បាទ!ចុះគ្នាច្រើនទេពេទ្យនៅហ្នឹង?

ស្រិ ៖ គ្នាច្រើន ។

ដានី ៖ ប្រហែលប៉ុន្មានទៅ?

ស្រិ ៖ យើមិនដឹងប៉ុន្មានទេ ។

ដានី ៖ មានស្រី មានប្រុស?

ស្រិ ៖ ចា៎មានស្រី មានប្រុស ។

ដានី ៖ ដូចថាមានចាស់មានក្មេងអត់?

ស្រិ ៖ មានចាស់ មានក្មេងនៅហ្នឹងទាំងអស់នៅរួមគ្នា ។

ដានី ៖ អ៊ំនៅគាឡៅរយៈពេលប៉ុន្មានទៅ?

ស្រិ ៖ នៅរយៈពេលយូរដែរ អត់ដល់១ឆ្នាំទេ ។

ដានី ៖ កាលហ្នឹងអ៊ំអត់ទាន់រៀបការទេ?

ស្រិ ៖ អត់ទេ

ដានី ៖ ហើយអ៊ំផ្លាស់មកនៅណាទៀត?

ស្រិ ៖ ផ្លាស់មកនៅមន្ទីរវង្ស នៅពេទ្យមន្ទីរវង្ស ជិតផ្សារថ្មី នៅជិតសាលាស៊ីសុវត្ថក្រោយសាលាស៊ីសុវត្ថហ្នឹង ។

ដានី ៖ ពេទ្យអីគេហ្នឹង?

ស្រិ ៖ ពេទ្យគេហៅពេទ្យសេនាធិការ ។

ដានី ៖ ពេទ្យរបស់សេនាធិការ?

ស្រិ ៖ ចា៎! ពេទ្យព្យាបាលរបួស ។

ដានី ៖ កាលហ្នឹងពេទ្យមានច្រើនទេ?

ស្រិ ៖ ពេទ្យមានច្រើន ។

ដានី ៖ អ៊ំមានចាំពេទ្យអីខ្លះ?

ស្រិ ៖ មិនចាំទេភ្លេចអស់ហើយយូរហើយ ។

ដានី ៖ បាទ! ពីណាគេជាអ្នកគ្រប់គ្រងនៅពេទ្យសេនាធិការហ្នឹង?

ស្រិ ៖ ឈ្មោះ បង ឡាយ គាត់គ្រប់គ្រងនៅហ្នឹង ។

ដានី ៖ គាត់ចាស់ជាងឬក្មេងជាងអ៊ំ?

ស្រិ ៖ គាត់ចាស់ជាង ។

ដានី ៖ ស្រីឬប្រុស?

ស្រី ៖ ស្រី

ដានី ៖ ចុះអ៊ំ អឿន ធីរិទ្ធ គាត់ខស្បាហ៍ទៅពេទ្យដែរ?

ស្រី ៖ គាត់ទៅពេទ្យដែរ តែមិនដឹងគាត់ទៅពេទ្យណា ពេទ្យច្រើនចឹងអី ។

ដានី ៖ ប៉ុនពេទ្យរបស់អ៊ំគាត់ធ្លាប់ទៅទេ ពេទ្យសេនាធិការ?

ស្រី ៖ មិនដឹងអី គាត់ធ្លាប់ទៅដែរមិនដឹងព្រោះយូរហើយ យូរហើយភ្លេចអស់ហើយ ។

ដានី ៖ ចុះកាលហ្នឹងពេលអ៊ំចូលធ្វើពេទ្យហ្នឹងអ៊ំរៀបការឬនៅ?

ស្រី ៖ រៀបការហើយនៅពេទ្យហ្នឹង ។

ដានី ៖ កាលហ្នឹងម៉េចអ៊ំអាចរៀបរាប់ពីការរៀបការហ្នឹងយ៉ាងម៉េច ហើយអ៊ំម៉េចបានជួបអ៊ំប្រុស ពេលណាហើយម៉េចបានអ៊ំរៀបការនៅពេលហ្នឹង?

ស្រី ៖ ខ្ញុំកាលហ្នឹងយើងនៅជាមួយអង្គការ អង្គការចេះតែហៅរៀបចំទៅ ចេះតែរៀបទៅ ។

ដានី ៖ ចុះអ៊ំប្រុសគាត់នៅណាដែរ?

ស្រី ៖ នៅហ្នឹងជាមួយគ្នាហ្នឹង នៅពេទ្យជាមួយគ្នាហ្នឹង ។

ដានី ៖ អ៊ំប្រុសគាត់ធ្វើពេទ្យដែរ ពេទ្យផ្នែកខាងអី?

ស្រី ៖ ពេទ្យផ្នែកទូទៅ ពេទ្យព្យាបាលជំងឺទូទៅដូចតែគ្នាហ្នឹង ។

ដានី ៖ ចុះស្រុកកំណើតគាត់នៅខាងណាដែរ?

ស្រី ៖ ស្រុកកំណើតគាត់នៅតាខ្មៅ ។

ដានី ៖ គេរៀបការយ៉ាងម៉េចជំនាន់ហ្នឹង?

ស្រី ៖ រៀបការចាប់ដៃ ។

ដានី ៖ ចុះដល់ពេលអ៊ំរៀបការហើយអ៊ំធ្វើអីទៀតនៅពេទ្យហ្នឹងដដែលឬក៏?

ស្រី ៖ រៀបការហើយនៅពេទ្យហ្នឹងដដែល ។

ដានី ៖ អត់មានផ្លាស់ទៅណាទៀតទេ?

ស្រី ៖ អត់ទេអត់មានផ្លាស់ទៀតទេ ។

ដានី ៖ នៅពេទ្យហ្នឹងរហូតដល់ពេលណាទៀតទៅ?

ស្រី ៖ នៅពេទ្យហ្នឹងយូរដែរ ក្រោយម៉ោបានទៅនៅអ្នកលឿង ។

ដានី ៖ ដកទៅទាំងពីរនាក់ឬក៏ទៅមួយនាក់?

ស្រី ៖ ទៅពេទ្យទាំងអស់គ្នា ដកទៅពេទ្យនៅអ្នកលឿងនោះទាំងអស់គ្នា ។

ដានី ៖ ពេទ្យនៅអ្នកលឿងនោះគេព្យាបាលអីខ្លះទៅ?

ស្រី ៖ ព្យាបាលរបួសដូចតែគ្នា របួសទូទៅ ។

ដានី ៖ របួសហ្នឹងយ៉ាងម៉េច ប្រជាជនរបួសប៉ុក៏?

ស្រី ៖ ទ័ព

ដានី ៖ របួសមកពីខាងណាម៉ោ?

ស្រី ៖ មកពីខាងស្វាយរៀង ព្រៃវែង ។

ដានី ៖ កាលហ្នឹងអ្នកណាគេជាអ្នកផ្ចាស់ទៅ គេផ្ចាស់អ៊ំទៅឬអ៊ំសុំគេទៅ?

ស្រី ៖ គេផ្ចាស់ទៅ ។

ដានី ៖ ពីណាគេជាអ្នកផ្ចាស់ទៅ?

ស្រី ៖ មិនដឹងពីណាពីណីទេគ្នាច្រើនពេកភ្លេចអស់ហើយ ប្រធានពេទ្យគេហ្នឹង ។

ដានី ៖ ប្រធានពេទ្យគេឈ្មោះអីទៅ?

ស្រី ៖ ឈ្មោះបងឡាយ ឈ្មោះអីហ្នឹង ។

ដានី ៖ បងឡាយហ្នឹងគាត់មកពីខាងណា?

ស្រី ៖ មិនដឹងគាត់នៅណា មិនដែលដឹងប្រវត្តិគាត់ផងខ្ញុំដែលសួរ ។

ដានី ៖ បាទ!ចុះដល់ពេលមកនៅអ្នកលឿងហើយយ៉ាងម៉េចទៀតទៅ?

ស្រី ៖ មកនៅអ្នកលឿងហើយរត់ម៉ោ ម៉ោនៅនេះរហូតហ្នឹងនេះ ។

ដានី ៖ រត់ពីអ្នកលឿងម៉ោ មកនៅនេះរហូតម៉ង?

ស្រី ៖ រត់ពីអ្នកលឿងម៉ោ ម៉ោនៅភ្នំពេញ ដល់មកនៅភ្នំពេញសភាពការណ៍វាអត់ស្រួលនៅពេញ
ហ្នឹងវៃគ្នាក្ដឹងក្ដុងហ្នឹងក៏នាំគ្នារត់មកទៀតម៉ោ ។

ដានី ៖ រត់ម៉ោណាទៀតទៅ?

ស្រី ៖ ហ្នឹងរត់ម៉ោធ្លាក់ដីថៃ មកនៅហ្នឹង ។

ដានី ៖ ចុះអ៊ំកាលជំនាន់មុនហ្នឹងម៉េចបានអត់រត់ទៅផ្ទះ?

ស្រី ៖ រត់ទៅផ្ទះណាបើកាលហ្នឹងវារត់ទៅផ្ទះអត់រួចៗ បើកាលហ្នឹងនាំគ្នានៅភ្នំពេញហើយ កាលហ្នឹងរថក្រោះ៣-៤ បើកតាមស្ពានយើង ស្ពានក្បាលថ្នល់ហ្នឹងចូលម៉ោ៣-៤ហើយវាបាញ់រះដូចស្អីអញ្ចឹងហើយអ្នកណារត់ទៅណា រត់ទៅយើង៧៥ទៅអត់កើតបើវាម៉ោតាមច្រកហ្នឹងហើយ ដល់អញ្ចឹងរត់ចាក់មកពាយ័ព្យនេះវិញ រត់មកពាយ័ព្យរត់ម៉ោនេះបណ្ដោយ ទៅ ។

ដានី ៖ កាលហ្នឹងរត់ម៉ោតែអ៊ំឬមានគ្នាច្រើនដែរ?

ស្រី ៖ គ្នាច្រើន ។

ដានី ៖ វត់យ៉ាងម៉េច អ៊ំអាចរៀបរាប់ដូចថាដំណាក់កាលយើងរត់ពីមួយកន្លែងទៅមួយកន្លែង ហើយស្ថានភាពពេលហ្នឹងវាយ៉ាងម៉េចពិបាកឬស្រួលអីយ៉ាងម៉េចពេលហ្នឹង?

ស្រិ ៖ ពិបាកដែលហ្នឹងពេលរត់ ប៉ុនវាឈប់ច្រើនកន្លែងមិនដឹងរៀបរាប់ថាម៉េច ។

ដានី ៖ ឈប់ច្រើនកន្លែង?

ស្រិ ៖ ឈប់ច្រើនកន្លែង ដល់ណានេះទៅឈប់ទៅ មានកម្លាំងទៅចេះតែនាំគ្នាដើរទៅមុខទៀតទៅអស់កម្លាំងនាំគ្នាឈប់ទៅ ។

ដានី ៖ កាលហ្នឹងអ៊ំអត់ទាន់មានកូនទេ?

ស្រិ ៖ អត់ទេ ។

ដានី ៖ រត់តែពីរនាក់ប្ដីប្រពន្ធ?

ស្រិ ៖ អត់ទេ រត់ជុំតាមអន្ដភាព អ្នករត់ម៉ោជួបគ្នាចេះតែទៅជាមួយគ្នាអញ្ចឹងម៉ោមិនចាំអន្ដភាព ដែរវែហលរហូតតាមផ្លូវម៉ោទាំងអស់គ្នាម៉ោ កាត់ព្រៃកាត់ផ្សែរម៉ោ ។

ដានី ៖ អ្ហូ!កាត់ព្រៃ កាត់ផ្សែរម៉ោ?

ស្រិ ៖ ចុះមានផ្លូវពីណា កាលហ្នឹងសុទ្ធតែភ្នំនាំគ្នារត់កាត់ភ្នំហ្នឹង ។

ដានី ៖ ចុះដូចហូបចុកបានអីហូបចុកទៅពេលរត់អញ្ចឹង?

ស្រិ ៖ អត់ទៅ ស្ពាយអង្ករទៅចេះតែនាំគ្នាដាំទៅ បើអស់ក៏អត់ទៅ ទឹកអីបើដាច់ក៏ដាច់ទៅ ។

ដានី ៖ ចុះរត់ដំបូងរត់មកដល់ណាទៅ ដំបូង?

ស្រិ ៖ ហ៊ឺមិនដឹងនៅណាទេ ចេះតែរត់មករហូត អត់ចាំផ្លូវហ្នឹងទៀតផង ចេះតែរត់ទៅរហូតហាត់ត្រឹមណាឈប់សិនទៅ មានកម្លាំងចាំទៅទៀតទៅដូចខ្ញុំថាម៉េញអញ្ចឹង វាមិនដឹងវាមិនស្គាល់តាមផ្លូវ ។

ដានី ៖ ដល់ពេលចុងក្រោយមកនៅណា?

ស្រិ ៖ ពេលចុងក្រោយម៉ោនៅនេះ នៅម្ដុំចក្រីនេះ ។

ដានី ៖ ដល់ពេលចុងក្រោយដែរមកសំណាក់ហ្នឹងនៅកន្លែងចក្រីហ្នឹងម៉ង?

ស្រិ ៖ ចា៎!

ដានី ៖ នៅកន្លែងចក្រីហ្នឹងធ្វើអីទៅ?

ស្រិ ៖ គ្មានធ្វើអីផង មានកាកបាទគេចិញ្ចឹម ។

ដានី ៖ ចុះអ៊ើអ៊ំប្រុសគាត់ធ្វើអី?

ស្រិ ៖ អ៊ំប្រុសគាត់ក៏អត់មានធ្វើ ព្រោះគាត់ចាស់ហើយគាត់ចេះតែនៅដែរទៅ ។

ដានី ៖ នៅកន្លែងចក្រីហ្នឹងរយៈពេលប៉ុន្មានទៅ?

ស្រិ ៖ នៅចក្រីហ្នឹងរយៈពេលយូរដែរហើយ១ឆ្នាំ ។

ដានី ៖ ចុះអ៊ីដែលចូលទឹកដីថៃទេ?

ស្រិ ៖ ចូលដែរហ្នឹង ចូលទៅដែរ ប៉ុនគ្រាន់ចូលទៅកាលនៅ៨៥ នោះនៅបានយូរហ្នឹង ។

ដានី ៖ បាទ!កាលមុនហ្នឹង?

ស្រិ ៖ កាលរត់ចេញពីចក្រីទៅ មិនទៅនៅ៨៥ ចេញពី៨៥ម៉ោខ្ញុំម៉ោនៅនេះទៀត ។

ដានី ៖ អញ្ចឹងអ៊ំចេញពីចក្រីដីបូងម៉ោ មកនៅនេះ?

ស្រិ ៖ ចា៎!មកនៅនេះ ។

ដានី ៖ កន្លែងហ្នឹងគេហៅអីនៅដីបូង?

ស្រិ ៖ ខ្ញុំនៅនេះអត់ដឹងគេហៅអី ពីដីបូងម៉ោចេះតែនាំគ្នានៅតែមាត់អូរ គ្មានអ្នកណាហានមកនៅដល់នេះដងហ្នឹង ។

ដានី ៖ អ៊ូ!នៅតែមាត់អូរទេ?

ស្រិ ៖ ចា៎!ដូចថាមានគ្រាប់ផ្លោងម៉ោអញ្ចឹងចេះតែនាំគ្នាគេចទៅណាស់ មុនដីបូងគេហៅភូមិដូងៗដែរហ្នឹង ។

ដានី ៖ ចុះស្ថានភាពភូមិដូងម៉េចបានគេហៅភូមិដូង?

ស្រិ ៖ មានដើមដូងច្រើនគេចេះតែហៅទៅ ។

ដានី ៖ នៅជិតមាត់អូរហ្នឹងមានដើមដូងច្រើន?

ស្រិ ៖ មានដើមដូង គេចេះហៅភូមិដូងៗទៅ ។

ដានី ៖ ចុះកាលហ្នឹងសុទ្ធតែព្រៃ ម៉េចមានដើមដូង?

ស្រិ ៖ ព្រៃ ប៉ុន្តែក្រោយមានគេដាំដើមដូង ដាំអីនៅហ្នឹងវាជាប់ថៃវាកៀកថៃ ថៃវាដាំដូង ។

ដានី ៖ អ៊ូ!អញ្ចឹង?

ស្រិ ៖ ដល់ពេលអញ្ចឹងគេហៅចេះតែភូមិដូងៗ ចំការដូងវានៅជិតយើង តែតាមពិតដីយើងទាំងអស់នេះសុទ្ធតែព្រៃទេ ។

ដានី ៖ អញ្ចឹងយើងហៅភូមិដូងដោយសារតែមានចំការថៃនៅជិតហ្នឹងទេ?

ស្រិ ៖ ចា៎!វាជិតហ្នឹង ហើយឈ្មោះហើយគេដាក់ផ្លាកថាភូមិដូងៗបណ្តោយទៅ មិនដឹងហៅម៉េច ។

ដានី ៖ បាទ!កាលហ្នឹងយើងនៅតាមមាត់អូរអញ្ចឹងយើងធ្វើផ្ទះយ៉ាងម៉េច?

ស្រិ ៖ ធ្វើខ្ទមៗនៅតូចៗអញ្ចឹងទៅ ។

ដានី ៖ ខ្ទមប្រកស្បូវអីហ្នឹង?

ស្រី ៖ ចា៎!ប្រកស្បូវមានសង្កសីពីណាម៉ោ ។

ដានី ៖ កាលហ្នឹងអ៊ំធ្វើអីកាលមកនៅតាមអូរហ្នឹង?

ស្រី ៖ អត់មានធ្វើអីផង នៅតែផ្ទះ ។

ដានី ៖ អត់ដែលដឹកជញ្ជូនឲ្យគេទេ?

ស្រី ៖ អត់ទេ!ដឹកជញ្ជូនឯណាបើចាស់ហើយ ។

ដានី ៖ កាលហ្នឹងអ៊ំអាយុប៉ុន្មាន?

ស្រី ៖ មិនដឹងអាយុប៉ុន្មានទេ ភ្លេចហើយ ប៉ុន្តខ្ញុំអត់ដែលស្គាល់ជាតិដឹកជញ្ជូនគេទេ ។

ដានី ៖ អញ្ចឹងអ៊ំនៅតែផ្ទះទេអញ្ចឹង?

ស្រី ៖ ចា៎!ខ្ញុំមិនដែលជួបការដឹកជញ្ជូនគេផងតាំងពីចូលម៉ោ ។

ដានី ៖ អ្ហូ!ចុះអ៊ំប្រុស?

ស្រី ៖ អ៊ំប្រុសកាលមុនដឹកជញ្ជូនគេដែរនឹង ប៉ុន្តគាត់អត់ដែលបានទៅដឹកជញ្ជូនឆ្ងាយផង ។

ដានី ៖ ចុះគាត់អត់ទៅធ្វើកងទ័ពទេ?

ស្រី ៖ អត់ទេ!អត់មានធ្វើកងទ័ពកងអីទេគាត់មិនដែលធ្វើទេ ។

ដានី ៖ ចុះក្រែងជំនាន់ហ្នឹងប្រុសៗធ្វើកងទ័ព ស្រីៗគេជាអ្នកដឹកជញ្ជូន?

ស្រី ៖ ធ្វើកងទ័ពតែអ្នកណាដែលគេមានសុខភាពល្អគេធ្វើបាន អ្នកដែលសុខភាពមិនល្អគេអត់ទៅ ដែលហ្នឹង ចាស់ៗទៅគេអត់ប្រើដែរ ។

ដានី ៖ គេអត់ប្រើដែរ?

ស្រី ៖ ចា៎!

ដានី ៖ បាទ!អញ្ចឹងអ៊ំប្រុសគាត់នៅក្បែរៗអ៊ំស្រីដែរ?

ស្រី ៖ នៅហ្នឹងទៅ ។

ដានី ៖ បាទ!ដល់ពេលយប់ព្រលប់អីនៅជាមួយគ្នាដែរ?

ស្រី ៖ នៅជាមួយគ្នាដែរ ។

ដានី ៖ កាលហ្នឹងអ៊ំអត់ទាន់មានកូនទេ?

ស្រី ៖ អត់ទេ!ខ្ញុំទើមមានកូនចាប់ពីឆ្នាំ៨៣-៨៤នេះទេ ។

ដានី ៖ អ្ហូ!៨៣-៨៤នេះហើយ?

ស្រី ៖ ចា៎!

ដានី ៖ ចុះកាលហ្នឹងពិបាកម៉េចទៅ កាលមកនៅកាលពីដំបូងមកនៅធ្វើខ្ទមធ្វើអីនោះ?

ស្រិ ៖ កាលហ្នឹងមកនៅតាមអូរថាពិបាកក៏ដូចមិនពិបាកដែរ ព្រោះកាលហ្នឹងមានកាកបាទជួយចិញ្ចឹមហើយ ។

ដានី ៖ មានកាកបាទគេជួយចិញ្ចឹមហើយ?

ស្រិ ៖ ចា៎!កាលហ្នឹងកាកបាទគេជួយដឹកអង្ករអីយកមកចែកកន្លែងក្បាលស្ពាននេះ កន្លែងភូមិដូង នេះ ។

ដានី ៖ ហូបចុកគ្រប់គ្រាន់ទេ?

ស្រិ ៖ អត់ខ្វះអីដែរទេ គេដឹកយកមកឲ្យមានអង្ករ មានត្រីខ មានខ្ទាញ់ ហើយត្រីប្រលាក់អញ្ចឹងរបស់គេមានម៉ាចប់ហ្នឹង ។

ដានី ៖ ចុះកាលហ្នឹងយើងអត់មានដាំប្រកបរបរបានផលអីទេ?

ស្រិ ៖ អត់មានដាំអីផងសុទ្ធតែមីន អត់ហានចេញទៅណាផង ។

ដានី ៖ អញ្ចឹងកាលឆ្នាំ៨០កាលមកនៅហ្នឹងនៅមានមីនដែរ?

ស្រិ ៖ ឆ្នាំ៨០ហ្នឹងនៅមានសុទ្ធតែមីន នៅហ្នឹងអីក៏សុទ្ធតែព្រៃដែរ ។

ដានី ៖ អញ្ចឹងអត់មានធ្វើអីទេ នៅតែផ្ទះទេ?

ស្រិ ៖ ចា៎!នៅតែផ្ទះ ។

ដានី ៖ ចុះបើមានជំងឺអីយើងទៅព្យាបាលនៅណា?

ស្រិ ៖ ជំងឺពេទ្យរួមគេមាន ។

ដានី ៖ ពេទ្យអី?

ស្រិ ៖ ពេទ្យរួមគេ ពេទ្យគេសម្រាប់ព្យាបាលរួម អ្នកណាឈឺទៅឲ្យពេទ្យគេមើលអត់អស់លុយទេ

ដានី ៖ ចុះកាលហ្នឹងអ៊ំមានឈឺដែលឬអត់?

ស្រិ ៖ ឈឺដែលហ្នឹងមានជំងឺគ្រុនចាញ់ដែរ ។

ដានី ៖ ឈឺគ្រុនចាញ់យើងទៅពេទ្យទៅ?

ស្រិ ៖ ទៅពេទ្យទៅ ពេទ្យគេមើលដាក់សេរ៉ូមដាក់អីឲ្យ គេអត់មានយកលុយទេកាលហ្នឹង ។

ដានី ៖ អញ្ចឹងអត់ពិបាកទេ?

ស្រិ ៖ អត់ពិបាកអីដែរ កាលហ្នឹងមានកាកបាទវាមិនសូវពិបាកទេ ធម្មតាតែពិបាកតែរឿងអត់លុយចាយវាពិបាកហើយ ប៉ុនកាលហ្នឹងវាមិនសូវចាយលុយអីផង ។

ដានី ៖ បាទ!នៅតែក្នុងព្រៃ?

ស្រិ ៖ ចា៎! នៅតែក្នុងព្រៃ វាពិបាកតែមីនវាពិបាកដែលហ្នឹង មួយថ្ងៃៗ ឃើញតែរបួសឃើញតែសែងដាប់ដែលហ្នឹង ។

ដានី ៖ ចុះក្រោយម៉ោពួថាយួនហើយកងទ័ពរដ្ឋកម្ពុជាគេវ៉ៃចូលម៉ោយើងទៅនៅដីថៃ?

ស្រិ ៖ កាលពេលហ្នឹងយើងទៅនៅដីថៃ ។

ដានី ៖ ទៅនៅដីថៃបានយូរទេ?

ស្រិ ៖ បើយួនមកនៅបានយូរ យើងនៅយូរទៅ បើយួននៅឆាប់យើងនៅឆាប់ដែរតាមដាក់ស្ដែង

ដានី ៖ ដល់ពេលមានមីនចាប់ពីពេលណាបានមានមីន?

ស្រិ ៖ មិនដឹងពេលណាទេ ម៉ោឃើញតែមីនម្ដង មិនដឹងពេលណាទេ ។

ដានី ៖ ចុអ្នករបួស ស្លាប់អីច្រើនទេស្លាប់ដោយសារមីនអី?

ស្រិ ៖ ច្រើនណាស់ស្លាប់ ។

ដានី ៖ ចុះធ្វើម៉េចកាលហ្នឹងយើងដោះអីធ្វើម៉េច?

ស្រិ ៖ យើងដោះទៅ យើងដោះខ្លួនយើងខ្លះទៅ ។

ដានី ៖ ចុះអ៊ំប្រុសអីគាត់ចេះដោះមីនដែរឬអត់?

ស្រិ ៖ កាលហ្នឹងគាត់ចេះដោះដែរហ្នឹង ។

ដានី ៖ គាត់ចេះដោះដែរ?

ស្រិ ៖ ចា៎!

ដានី ៖ ចុះអ៊ំអត់ចេះដោះទេ?

ស្រិ ៖ អត់ទេខ្លាច ខ្ញុំទៅជិតមិនហានទៅផង ព្រោះឃើញគេរបួសដាច់ដៃដាច់ជើងអញ្ចឹងខ្លាចចង់ ងាប់ ។

ដានី ៖ ចុះផ្ទះអ៊ំដីបូងនៅម្ដុំណា?

ស្រិ ៖ ផ្ទះខ្ញុំនៅមាត់អូរនោះ ។

ដានី ៖ ចុះឆ្នាំណាផ្លាស់មកនៅនេះ?

ស្រិ ៖ មិនដឹងឆ្នាំប៉ុន្មានទេភ្លេចហើយ ប្រហែលជិត១០ឆ្នាំហើយ ។

ដានី ៖ ទឹមជិត១០ឆ្នាំទេ?

ស្រិ ៖ ចា៎!

ដានី ៖ អញ្ចឹងមុននៅមាត់អូរ?

ស្រិ ៖ ចា៎នៅមាត់អូរ ហ្នឹងផ្ទះមេភូមិនោះក៏នៅមាត់អូរនៅជុំគ្នាទាំងអស់ ។

ដានី ៖ អញ្ចឹងទឹមម៉ោ?

ស្រី ៖ ចាំម៉ោនេះម៉ោទាំងអស់គ្នា ។

ដានី ៖ ចុះកាលគេធ្វើសមាហរណកម្មដំបូង ដូចថាសមាហរណកម្មឆ្នាំណា?

ស្រី ៖ មិនទេភ្លេចអស់ហើយ?

ដានី ៖ ចុះយ៉ាងម៉េចពេលគេធ្វើសមាហរណកម្មអ៊ីមាននៅចាំដែរ? គេបែងចែកភូមិ ឃុំអីយ៉ាង ម៉េចដែរ?

ស្រី ៖ ទេមិនសូវដឹងដែរ ខ្ញុំមិនសូវបានធ្វើ ភ្លេចអស់ហើយយូរហើយ ។

ដានី ៖ ចុះកាលពីមុនមានឈ្មោះភូមិវាលហាត់ ឈ្មោះអីភូមិកណ្ដាល កាលពីមុនសមាហរណកម្ម មានឈ្មោះភូមិអីអញ្ចឹងដែរឬអត់?

ស្រី ៖ ទេពីមុនម៉ោអត់មានផង គេទឹមដាក់ក្រោយនេះដែរ ទឹមដាក់ម៉ោនិយាយរួមយើងផ្ដាច់ខ្លួន ហើយគេរៀបចំជាភូមិជាឃុំនេះឡើងវិញទៅ ពេលយើងឈប់ឈ្លោះគ្នាគេរៀបចំជាភូមិឃុំ

ដានី ៖ ម៉េចបានគេរៀបចំដាក់ឈ្មោះជាភូមិអញ្ចឹងៗ?

ស្រី ៖ មិនដឹងម៉េចដែរ មិនដឹងដែរ ។

ដានី ៖ ព្រោះកាលពីមុនអត់មានឈ្មោះទេ?

ស្រី ៖ អត់ទេ!

ដានី ៖ ចុះដល់ពេលគេផ្ដាច់ខ្លួនគេរៀបចំភូមិឃុំ ដូចថាគ្រួសារមួយៗគេចែកដីធ្លីឲ្យឬក៏យើងទៅចាប់ ខ្លួនយើង?

ស្រី ៖ គេអត់ចែកឲ្យផង យើងចាប់ ។

ដានី ៖ ដីនៅនេះអ៊ំចាប់ទេ?

ស្រី ៖ ដីខ្ញុំនៅនេះខ្ញុំទិញទេ ទិញផ្ទះហ្នឹង ផ្ទះមេភូមិដូចថាម៉ោពីអូរទាំងអស់គ្នាអញ្ចឹងគាត់លក់ ថោកៗចែកគ្នានៅអញ្ចឹងទៅណាំ ។

ដានី ៖ អ៊ូកាលដំបូងគាត់មកចាប់ដីនៅហ្នឹង?

ស្រី ៖ ចាំ!

ដានី ៖ គាត់ចាប់ហើយគាត់លក់ឲ្យ?

ស្រី ៖ គាត់ចែកឲ្យ!

ដានី ៖ ចុះកាលពីផ្ដាច់ខ្លួនដំបូងមីងរកស៊ីអីទៅ?

ស្រិ ៖ ផ្តាច់ខ្លួនដំបូងកាកបទគេចិញ្ចឹម! យើងទៅកាប់ចំការដាំជាពោតជាអីទៅ ធ្វើលក់ឲ្យថៃណា៎ ដល់ពេលកាកបទគេឈប់ចិញ្ចឹមយើងរកស៊ីខ្លួនឯង! ដាំពោតបានយើងចេះតែទូលយកទៅលក់ឲ្យថៃទៅ!

ដានី ៖ បាទ!

ស្រិ ៖ សណ្តែកអីហ្នឹង!

ដានី ៖ ដាំហើយទូលយកទៅលក់ឲ្យថៃ?

ស្រិ ៖ ចា៎!

ដានី ៖ ដីយើងចាប់ខ្លួនឯងឬក៏គេចាប់ខ្លួនឯង?

ស្រិ ៖ ដីយើងចាប់ខ្លួនយើង!

ដានី ៖ អ៊ឹចាប់ដីបានច្រើនទេ?

ស្រិ ៖ ដីបានតិចដែរ?

ដានី ៖ បានប៉ុន្មាន?

ស្រិ ៖ ដីបាន៣០,៤០រ៉ៃ!

ដានី ៖ ដីហ្នឹងដីចំការ?

ស្រិ ៖ ដីចំការ!

ដានី ៖ ចុះដីស្រែ?

ស្រិ ៖ ដីស្រែប្រហែលពីររ៉ៃ!

ដានី ៖ ពីររ៉ៃហ្នឹងយើងធ្វើបានហូបចុកគ្រប់គ្រាន់ដែរឬអត់?

ស្រិ ៖ អត់ទេ ធ្វើអត់ដែលកើតផង!

ដានី ៖ ធ្វើអត់ដែលកើត?

ស្រិ ៖ ចា៎! ទោះបីធ្វើកើតក៏វាបានតិច!

ដានី ៖ អញ្ចឹងដល់ពេលនេះយើងទិញស្រូវថែមទៅ?

ស្រិ ៖ ទិញអង្ករហូប!

ដានី ៖ បើនៅចំការអ៊ឹធ្វើបានច្រើន?

ស្រិ ៖ ចំការបើធ្វើបានច្រើនទៅ តែបើធ្វើអត់បានវាអត់ដែរ ស៊ីសងលើមានទឹកភ្លៀង បើមានភ្លៀងទៅយើងធ្វើបានផលទៅ បើអត់ភ្លៀងយើងអត់ដែរ តែបើដូចឆ្នាំនេះពីដើមដៃវាំងខូចពោតខូចអីអស់ ទាល់តែចុងដៃអត់មានអ្នកណាហានធ្វើស្រែណាឃើញចោលគ្រប់តែគ្នា

ដល់ពេលភ្លៀងៗហួស ភ្លៀងទាល់តែអ្នកដាំសណ្តែកគ្នាខូចអស់ ខ្ញុំអត់ដាំគេខ្ញុំខ្ជិលខ្ញុំដាំពោត ហើយចោលបណ្តោយទៅ ។

ដានី ៖ ចុះអ៊ុំតាំងពីយើងផ្លាច់ខ្លួនម៉ោយើងធ្វើការរកស៊ីខ្លួនឯងអញ្ចឹង ដូចថាជីវភាពរស់នៅម៉េចដែរ បើយើងប្រៀបធៀបកាលពីមុនកាល ពីមិនទាន់ផ្តាច់ខ្លួនដូចថា យើងមានកាកបាទគេចិញ្ចឹម ដូចថាយើងរកស៊ីខ្លួនឯងយ៉ាងម៉េចដែរ ដូចថាមួយណាស្រួលជាង?

ស្រិ ៖ អាហ្នឹងបើយើងនិយាយថាកាកបាទគេចិញ្ចឹមវាស្រួលម្យ៉ាង បើយើងរកខ្លួនយើងក៏វាម្យ៉ាង ដែរ វាចេញញើសខ្លួនយើង ដឹងថាខ្វះខាតប៉ុណ្ណា គ្រប់ប៉ុណ្ណាអីហ្នឹងយើងធ្វើខ្លួនយើង ហត់ខ្លួនយើងអាហ្នឹងដឹងហើយ គិតថាម្យ៉ាងម្នាក់ ។

ដានី ៖ បើតាមអ៊ុំចូលចិត្តមួយណាជាង?

ស្រិ ៖ ខ្ញុំមិនចូលចិត្តឲ្យគេចិញ្ចឹងទេ សុខចិត្តរកខ្លួនឯងអញ្ចឹងហើយស្រួល

ដានី ៖ សុខចិត្តធ្វើខ្លួនឯងស្រួលជាង?

ស្រិ ៖ ចាំ! យើងធ្វើខ្លួនឯងទៅ យើងមានលុយមានកាកអី យើងចង់ចាយយើងចាយខ្លួនយើងទៅ គ្មានពីណាគេសោមនស្សជាមួយយើង ។

ដានី ៖ ចុះអ៊ុំណាបានអ៊ុំទៅលេងស្រុកភូមិនៅកោះធំ?

ស្រិ ៖ ខ្ញុំទឹមឆ្នាំនេះខ្ញុំអត់ទៅ កាលឆ្នាំទៅខ្ញុំទៅភ្ជុំដែរ ឆ្នាំនេះអត់ទៅវាភ្លៀងដាច់ផ្លូវពេកខ្ជិលទៅ ។

ដានី ៖ ចុះអ៊ុំលើកទី១ អ៊ុំបែកពីផ្ទះឆ្នាំ៧០ជាងបែកពីផ្ទះ ហើយបានទៅលេងផ្ទះវិញនៅឆ្នាំណា?

ស្រិ ៖ ហ៊ឺ! មិនឆ្នាំណាទេ ភ្លេចហើយទៅហូរហែរ ។

ដានី ៖ បាទ! ទៅដំបូងបំផុតដែលអ៊ុំបានទៅដំបូងបកផុត?

ស្រិ ៖ មិនដឹងតាំងពីអន្កាលណាម៉ោទេ យូរហើយភ្លេចអស់ហើយ ។

ដានី ៖ ទៅមុនផ្តាច់ខ្លួនឬក្រោយផ្តាច់ខ្លួន?

ស្រិ ៖ ទៅលេងផ្ទះទៅហូរហែរជាប់ដែរហ្នឹង ។

ដានី ៖ បាទ! ប៉ុន្តែទៅលើកទី១?

ស្រិ ៖ លើកទី១មិនដឹងអន្កាល់ណាម៉ោទេ យូរហើយភ្លេចហើយ ។

ដានី ៖ ចុះអ៊ុំកាលអ៊ុំទៅលេងផ្ទះលើកដំបូង ដូចថាបែកពីផ្ទះយូរ ទៅលេងផ្ទះពេលហ្នឹងអ៊ុំមាន អារម្មណ៍យ៉ាងណាដែរ?

ស្រិ ៖ ទេ! ដូចមិនមានអារម្មណ៍យ៉ាងម៉េចផង ។

ដានី ៖ ដូចថាយើងអារម្មណ៍ថានឹកថាប្លែកពីមុនដែរឬអត់ ដូចថាពីមុនយើងធ្លាប់រស់នៅជាមួយបងប្អូនឪពុកម្ដាយកាលពីនៅតូចៗ កាលនៅក្មេងៗយើងធ្លាប់រស់នៅជាមួយគ្នារាល់ថ្ងៃ យើងមានភាពស្និតស្នាលអញ្ចឹង ដល់ពេលយើងបែកយូររាប់ឆ្នាំបានទៅ ដូចថា២០-៣០ឆ្នាំបាន យើងទៅមួយដង ទៅលើកទី១ដូចថាមានអារម្មណ៍យ៉ាងម៉េច វាខុសប្លែកយ៉ាងម៉េច ម៉េចទៅដូចថាបានទៅលេងផ្ទះដំបូង?

ស្រី ៖ ទេដូចគ្មានអារម្មណ៍ម៉េចផង គ្រាន់តែថាបែកបងប្អូនយូរអញ្ចឹងវានឹកហើយនឹកបងប្អូនអញ្ចឹង ហើយទៅស្រុកភូមិក៏វាប្លែកទៅ បើនិយាយពីការរីកចំរើនគេរីកចំរើនវានៅស្រុកភូមិនោះ គេអត់មានរត់ដូចយើងនៅនេះ ។

ដានី ៖ ប៉ុន្តែប្លែកពីមុនទេ មនុស្សអី ពីមុនអឺស្គាល់មនុស្សស្និតស្នាល ដល់ពេលក្រោយម៉ោយើងបែកពីភូមិយូរ ភាពស្និតស្នាលវានៅដូចមុនដដែលឬខុសពីមុន?

ស្រី ៖ អត់អីទេ បងប្អូនខ្ញុំនៅតែស្និតស្នាលដដែល បែកគ្នាយូរក៏ដោយទៅនៅតែនឹកនៅតែរាប់រកគ្នាដូចតែមុនដដែលហ្នឹង ។

ដានី ៖ បាទ!ចុះញាតិមិត្ត?

ស្រី ៖ ញាតិមិត្តក៏អត់អី ។

ដានី ៖ គេនៅស្គាល់អ៊ីដែរ?

ស្រី ៖ គេអត់អីទេ ទៅអញ្ចឹងគេរត់អោបខ្ញុំគេនៅតែនឹក ពីមុនធ្លាប់នឹកគ្នាយ៉ាងម៉េចឥឡូវក៏នៅតែអញ្ចឹង ។

ដានី ៖ គេនៅតែចាំអ៊ីដែរ?

ស្រី ៖ ចាំ!គេនៅតែចាំ ។

ដានី ៖ អ៊ីអត់មានប្រែប្រួលទេទៅក្រោយ?

ស្រី ៖ អត់ផង

ដានី ៖ ចុះអ៊ីម៉េចបានអ៊ីអត់ចង់ទៅនៅស្រុកកំណើតវិញ?

ស្រី ៖ ខ្ញុំខ្ជិលទៅនៅ ដូចថាយើងនិយាយពីយើងកវែកកឆ្នាំនៅនេះយើង ដូចថាយើងនៅនេះយើងមានដីមានធ្លីគ្រាន់ធ្វើ ហើយដល់ពេលយើងទៅស្រុកយើងបានអីធ្វើ អញ្ចឹងបើយើងទៅយើងអត់មានដីមានធ្លីអីយើងទៅប្រកកោនជាមួយគេវាពិបាកណាស់ វាមិនដូចយើងនៅ នេះ បើទៅទាល់យើងរកលុយទិញខ្លួនយើងៗធ្វើផ្ទះនៅខ្លួនយើង ដល់ពេលអញ្ចឹងនឹកឃើញនៅនេះដូចថាវាទំម្លាប់នៅនេះហើយនៅនេះចុះ លែងចង់ទៅស្រុកហើយ ។

ដានី ៖ អញ្ចឹងដូចថាអ៊ំនៅនេះអ៊ំជាមួយអ្នកនៅនេះដូចថា អារម្មណ៍របស់អ៊ំបានផ្សាភ្ជាប់ជាមួយអ្នកនៅនេះយ៉ាងម៉េចដែរ?

ស្រី ៖ អត់ទេអត់មានអីផង ដូចតែបងដូចតែប្អូនអញ្ចឹងឯង ស្រឡាញ់គ្នា ធ្លាប់បែកពីណាពីណីម៉ោមកជួបជុំគ្នា ។

ដានី ៖ អញ្ចឹងដូចថាការរស់នៅនេះ ដូចថាអ៊ំទៅលេងស្រុកអីអ៊ំមាននឹកស្រុកនៅនេះដែរ?

ស្រី ៖ នឹកម៉ោនេះ បើនិយាយពីអារម្មណ៍ទៅនៅនោះមានតែបងប្អូន ដ៏យូរៗចាត់ទុកនេះជាដូចជាភូមិកំណើតវិញហើយ យូរៗយើងបានទៅមួយដង ហើយនេះយើងនៅយូរហើយ ។

ដានី ៖ បាទ!នៅយូរហើយ ប៉ុន្តែពួកគាត់សុទ្ធតែអ្នកក្រៅប៉ុននៅជាមួយគ្នាយូរហើយ ចាត់ទុកគ្នាដូចជាបងប្អូន?

ស្រី ៖ ចា៎!បងប្អូនរាល់ថ្ងៃហ្នឹងបើយើងមានការឈឺឆ្កាត់អី យើងចេះគ្នាទៅវិញទៅម៉ោទាំងអស់គ្នាគ្មានប្រកាន់ទេ ។

ដានី ៖ ចង់ជាងនៅស្រុកទៀត?

ស្រី ៖ ស្និតស្នាលជាងបងប្អូនផងម៉ោនៅនេះ ដូចថាពឹងពាក់អីគ្នាបាន អត់ពីមួយទៅមួយបាន ។

ដានី ៖ ជួយគ្នាទៅវិញទៅម៉ោ?

ស្រី ៖ ចា៎!ជួយគ្នាទៅវិញទៅម៉ោ ។

ដានី ៖ ចុះបងប្អូនអ៊ំនៅស្រុកមានដែលមកលេងអ៊ំនៅនេះដែរឬអត់?

ស្រី ៖ បងប្អូនខ្ញុំ ដែលមកលេងលើកមុនមួយដងដែរ យូរហើយ ម៉ោខាងប្អូនថ្លៃ ។

ដានី ៖ បាទ!បងប្អូនអ៊ំបង្កើតអត់ដែលម៉ោទេ?

ស្រី ៖ អត់ទេ!បងប្អូនខ្ញុំបង្កើតអត់ដែលម៉ោទេ នៅឆ្ងាយៗ ។

ដានី ៖ ពេលអ៊ំទៅលេងផ្ទះនៅកោះធំ អ៊ំបានជួបពួកគាត់ដែរ?

ស្រី ៖ ជួបដែរ អ្នកនៅហ្នឹងជួបទៅ អ្នកនៅផ្សេងទៅអត់ជួបទៅ ព្រោះបងប្អូននៅបែកៗគ្នា ។

ដានី ៖ បាទ!ចុះអ៊ំមានដែលបានទៅលេងភ្នំពេញទៀតទេក្រោយៗនេះ?

ស្រី ៖ អត់ដែលបានទៅផង ។

ដានី ៖ តាំងពីជំនាន់៣ឆ្នាំម៉ោ ក្រោយទៀតអត់ដែរបានទៅពេញទៀតទេ?

ស្រី ៖ ធ្លាប់បានទៅ ទៅលេងពេញកាលឆ្នាំទៅខ្ញុំទៅ ទៅខែ៨-៩ហ្នឹងខ្ញុំទៅលេងពេញដែរ ។

ដានី ៖ មានបងប្អូននៅភ្នំពេញដែរ?

ស្រី ៖ បងប្អូនមាននៅក្បាលថ្នល់ ច្បារអំពៅ ។

ដានី ៖ អ៊ំមើលខុសប្លែកពីកាលជំនាន់ពាន្នាំម៉េចទៅ នៅភ្នំពេញ?

ស្រិ ៖ សប្បាយឥឡូវគេរៀបរយបានស្អាតបាត ។

ដានី ៖ ខុសពីជំនាន់ពាន្នាំ?

ស្រិ ៖ ចា៎!ខុសឆ្ងាយណាស់ ។

ដានី ៖ ពីជំនាន់ពាន្នាំទិដ្ឋភាពម៉េចដែរនៅពេញ?

ស្រិ ៖ ធម្មតាវាសម័យសង្គ្រាម ហើយម៉ោឥឡូវអត់មានសង្គ្រាមវាខុសគ្នាអញ្ចឹងឯង ។

ដានី ៖ ចុះកាលជំនាន់ពាន្នាំមានសង្គ្រាមពីណាអត់មានផងហ្នឹង?

ស្រិ ៖ កាលជំនាន់ពាន្នាំអត់មានសង្គ្រាម តែជម្លៀសប្រជាជនចេញអស់ហើយហ្នឹង មានអ្នកណាគេនៅពេញអត់ផង នៅតែអ្នកធ្វើការនៅពេញហ្នឹងឯង នៅតែអ្នកធ្វើការតាមកងទ័ពតាមអង្គភាពហ្នឹង ។

ដានី ៖ អញ្ចឹងស្ងាត់អញ្ចឹង?

ស្រិ ៖ ស្ងាត់!ស្ងាត់ណាស់ ។

ដានី ៖ ខុសពីឥឡូវ?

ស្រិ ៖ ចា៎!ឥឡូវគេអ៊ូអរណាស់ កន្លែងធ្លាប់នៅទៅឥឡូវចង់វង្វេងហើយ ។

ដានី ៖ ចុះកាលជំនាន់ពាន្នាំ អ៊ំមានដែលឃើញមនុស្សស្លាប់មនុស្សអីដែរឬអត់?

ស្រិ ៖ ទេ!ខ្ញុំមិនដឹងទេ ខ្ញុំមិនដែលបានឃើញផង ។

ដានី ៖ អត់ដឹងថាជំនាន់ហ្នឹងមានស្លាប់មនុស្សមានអីទេ?

ស្រិ ៖ អត់ដឹងផង ខ្ញុំដែលបានដើរទៅណាគេឲ្យបានដឹងផង ។

ដានី ៖ ចុះកាលជំនាន់ហ្នឹងអ៊ំហូបចុកអីបានគ្រប់គ្រាន់ទេ?

ស្រិ ៖ ហូបចុកអត់ទេ អត់ដែលខ្វះខាតអីដែរទេ ខ្ញុំនៅពេទ្យមើលអ្នកជំងឺ ។

ដានី ៖ ចុះអ៊ំឥឡូវអ៊ំមានដែលឮ ដែលមើលពត៌មាន ដែលទាក់ទងពីតុលាការគេកាត់ទោសពួកអ៊ំៗពួកមេដឹកនាំខ្មែរក្រហមនៅភ្នំពេញអ៊ំមានដែលស្តាប់ពត៌មាន មើលទូរទស្សន៍ ឮពត៌មានអីដែរឬអត់?

ស្រិ ៖ ដែលឮ ដែលមើលឃើញដែលហ្នឹង ។

ដានី ៖ អ៊ំមើលឃើញម៉េចដែលអ៊ំ?

ស្រិ ៖ ទេ!អាហ្នឹងស្រេចតែរឿងរបស់គេអ្នកធំៗ ។

ដានី ៖ ស្រេចតែអ្នកធំ?

ស្រិ ៖ ចា៎!

ដានី ៖ បើតាមចិត្តអ៊ំវិញគុលាការដែលគេបង្កើតឡើងការកាត់ទោសហ្នឹង ត្រឹមត្រូវដែរឬអត់ទេ បើតាមចិត្តអ៊ំវិញ?

ស្រិ ៖ ទេ!ខ្ញុំមិនដឹងទេ ស្រេចតែគេ ។

ដានី ៖ តាមចិត្តអ៊ំផ្ទាល់អ៊ំឃើញគេកាត់ហ្នឹង អ៊ំគិតថាហេស៎កាត់ហ្នឹងមិនត្រឹមត្រូវទេដោយសារមូលហេតុអី កាត់នេះត្រឹមត្រូវដោយសារមូលហេតុអី តាមចិត្តអ៊ំវិញអ៊ំគិតថាម៉េចដែរ?

ស្រិ ៖ ខ្ញុំអត់មានគិតទេ គិតថារឿងហ្នឹងជារឿងរបស់អ្នកធំ អ្នកធំដោះស្រាយម៉េចដោះស្រាយ ទៅកាត់ទោសម៉េចកាត់ទៅខ្ញុំអត់ដឹងដែរ មិនដឹងដែររឿងហ្នឹងជារឿងរបស់រាជរដ្ឋាភិបាលទេធ្វើម៉េចធ្វើទៅ ខ្ញុំយល់ថាអញ្ចឹងឯង អត់មានយល់ថាអ្វីគេកាត់ទោសខ្មែរក្រហមហើយវាខុសគោលការណ៍អីម៉េចៗខ្ញុំអត់មានដឹងទេ ខ្ញុំដឹងតែថារឿងហ្នឹងជារឿងរបស់រដ្ឋាភិបាល ទេ បើគាត់ថាកាតទោសខ្មែរក្រហមទៅវាសមហេតុសមផលយ៉ាងម៉េចក៏ស្រេចតែរដ្ឋាភិបាលទៅចុះខ្ញុំអត់មានទាស់ទេ ខ្ញុំប្រជាជននៅនេះខ្ញុំអត់ដឹងដែរ ធ្វើម៉េចធ្វើទៅ ។

ដានី ៖ ចុះអ៊ំៗធ្លាប់ស្គាល់អ៊ំពីអ្នកដឹកនាំនោះដែរ ធ្លាប់ស្គាល់គាត់ ភាពស្និតស្នាល ដូចថាគាត់មនុស្សយ៉ាងម៉េចដែរ?

ស្រិ ៖ ហ៊ឺ!មិនដឹងទេ

ដានី ៖ អ៊ំធ្លាប់ស្គាល់ពួកគាត់ដែរ?

ស្រិ ៖ ស្គាល់ក៏ខ្ញុំមិនស្គាល់ច្បាស់ដែរ ខ្ញុំមិនដែលទៅណាផង ខ្ញុំដូចថានៅមួយដុំណានៅតែមួយដុំ ហ្នឹង ។

ដានី ៖ ស្គាល់អ៊ំអៀង សារី ដែរ?

ស្រិ ៖ អ្ហូ!អ៊ំ អៀង សារី ស្គាល់គាត់ម៉ោភូមិដូង

ដានី ៖ គាត់ម៉ោភូមិដូង?

ស្រិ ៖ ចា៎! ប៉ុន្តែការស្និតស្នាលឬមិនស្និតស្នាលព្រោះខ្ញុំអត់ដែលបាននៅជាមួយគាត់ផង ដូចថាវានៅឆ្ងាយ ។

ដានី ៖ បាទ!ចុះអ៊ំ អៀង ធីរិទ្ធ?

ស្រិ ៖ អ៊ំ អៀង ធីរិទ្ធហ្នឹងក៏ខ្ញុំអត់ដែលបាននៅជាមួយគាត់ គ្រាន់តែថាឮឈ្មោះហើយឃើញមុខឃើញអីអញ្ចឹងទៅណាស៎ ។

ដានី ៖ បាទ!

ស្រិ ៖ ចា៎!តែការរស់នៅជាមួយគាត់ស្និតស្នាលអត់មានទេ ខ្ញុំអត់ដែលបាននៅទេ ។

ដានី ៖ អ៊ូ!អញ្ចឹងទេ?

ស្រិ ៖ ចាំ!

ដានី ៖ ដូចថាខ្ញុំចង់ដឹងតែថាអ៊ូគាត់ម៉េចដែរអីម៉េចដែរ ព្រោះគាត់អ្នកធំនោះ ដូចថាគាត់យ៉ាងម៉េច ការរស់នៅរបស់គាត់ គាត់រស់រាយឬក៏យ៉ាងម៉េច តែអឹងអត់ដែលនៅជាមួយគាត់?

ស្រិ ៖ អត់ដែលនៅជាមួយគាត់ទេ អត់ដែលនៅជុំជាមួយគាត់ផង ប៉ុន្តែបើយើងនិយាយថាបើយើងដើរជួបគាត់អញ្ចឹងមានអីគាត់ គាត់រួសរាយទាក់ទាក់ធម្មតា គាត់ឃើញយើងវិញក៏គាត់មិនស្មើងដែរ គាត់ធ្លាប់ស្គាល់អញ្ចឹងគាត់ហៅទៅ ។

ដានី ៖ ចុះអ្នកគ្រប់គ្រងនៅម៉ាឡៃដំបូងអ្នកណាគេ អ៊ំអៀង សារី ឬមិនមែន?

ស្រិ ៖ នៅម៉ាឡៃយើងនេះ?

ដានី ៖ កាលម៉ោនៅតាមដងអូរ?

ស្រិ ៖ គ្រប់គ្រងនៅនេះ?

ដានី ៖ បាទ!

ស្រិ ៖ អ៊ំ អៀង សារី អ៊ំអីហ្នឹងឯង

ដានី ៖ ចុះអ្នកគ្រប់គ្រងផ្ទាល់?

ស្រិ ៖ ហ៊ុ!មិនដឹងពីណាពីណីទេគ្នាច្រើន ។

ដានី ៖ តែអ៊ំ អៀង សារី គាត់មិននៅហ្នឹងណាំ?

ស្រិ ៖ អ៊ំ អៀង សារី កាលហ្នឹងគាត់នៅភូមិដូង គាត់នៅ (ដ២៥) ផ្ទះគាត់នៅភូមិដូងដែរកាលមុន ។

ដានី ៖ ចុះពូហុង ពូចៀម កាលមុនគាត់នៅហ្នឹងដែរ?

ស្រិ ៖ កាលមុនគាត់នៅហ្នឹងដែរ កាលមុនគាត់ដឹងនាំដែលហ្នឹង អ្នកគ្រប់គ្រងពូហុង ។

ដានី ៖ ស្គាល់គាត់ច្បាស់ៗដែរ?

ស្រិ ៖ ចាំ!

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណអ៊ំច្រើន ដែលចំណាយពេលសំណេះសំណាលជាមួយខ្ញុំ ដែលទាក់ទងនឹងជីវិតរបស់អ៊ំ ហើយមានអីសួរបន្ថែមនូវអារអ៊ីដែលខ្ញុំអត់បានសួរទៅអ៊ំទេ?

ស្រិ ៖ អត់ៗមានអីផង ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណច្រើន ។

«ចប់»